ដោះស្រាយវិវាទការងារ

# ព្រឹត្តិប័ត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងការកាត់សេចក្តី ដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច

កុម្ភៈ ២០១១

## ការដោះស្រាយវិវាទការងារដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលបានវិវាទការងារចំនួនដប់សំណុំរឿង ដែលនៅក្នុងនោះមានសំណុំរឿងចំនួនប្រាំមួយ ដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១០ ដោយនិយោជក និង សហជីពពាក់ព័ន្ធដែល កំពុងធ្វើប្រតិបត្តិការរបស់ខ្លួននៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។ ភាគីហត្ថលេខីបានព្រមព្រៀងគ្នាទទួលយកការសម្រេចសេចក្តីជាប់កាតព្វកិច្ច និងជាស្ថាពរដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីសិទ្ធិ។

ជាសរុប ចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលវិវាទការងារចំនួន ២៩សំណុំរឿង។ តារាងខាងក្រោម បង្ហាញសំណុំរឿងសរុបដែលទទួលបានដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយបានបែងចែកសំណុំរឿង ដែលមានអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលមិនមានអនុសារណៈនៃការយោគយល់គ្នា។



# ការសង្កេតលើការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលមានសេចក្តីសម្រេចជាប់ភាគពូកិច្ច

សម្រាប់រយៈពេល នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១១ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការចាប់អារម្មណ៍ លើការសង្កេតមួយចំនួន រួមមានទាំង ការជម្រុញឱ្យមានការអភិវឌ្ឍន៍ និងបញ្ហាប្រឈមជាជំហានដំបូង ទាក់ទងនឹងសំណុំរឿងវិវាទការងារ ដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា ។

១. ការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

- នៅក្នុងសំណុំរឿងបី ភាគីវិវាទបានឈានដល់កិច្ចព្រមព្រៀងបញ្ចប់ជំលោះមុនក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីសម្រេច ។
- នៅក្នុងសំណុំរឿងមួយ ភាគីនិយោជក និងសហជីពសំណូមពរ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យពន្យារដំណើរការអាជ្ញាកណ្តាលដើម្បីឱ្យពួកគេមានពេលវេលាបន្ថែមសម្រាប់ការចចារបញ្ចប់ជំលោះ ។
- ជាទូទៅ ភាគីវិវាទបានបង្ហាញឆន្ទៈ និងការខិតខំប្រឹងប្រែងខ្ពះខ្នែងរបស់ពួកគេដើម្បីចចារដោយមានទស្សនៈក្នុងការបញ្ចប់វិវាទ ។

២. បញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងសំណុំរឿងពីរ ដែលពាក់ព័ន្ធនឹងសហគ្រាស សហជីព និងនិយោជកដូចគ្នា ភាគីសហជីពមិនបានចូលរួម នៅក្នុងដំណើរការអាជ្ញា-កណ្តាល សម្រាប់សំណុំរឿងដែលសហជីពខ្លួនឯងជាអ្នកផ្តើមបណ្តឹង ។ នៅក្នុងចំណោមសំណុំរឿងទាំងនេះសំណុំរឿងមួយពាក់ព័ន្ធនឹងកូដកម្មដែលធ្វើឡើងដោយភាគីសហជីពមុនដំណើរការអាជ្ញាកណ្តាល ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាឱ្យចូលធ្វើការវិញ ខាងកម្មករនិយោជិតក៏បានត្រលប់ចូលធ្វើការ និងរង់ចាំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដល់អង្គសេចក្តីនៃសំណុំរឿងរបស់ពួកគេ ។

+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=

**អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**ដើម្បីឈប់ទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ**
dvandeth@arbitrationcouncil.org **ជាមួយប្រធានបទ** “Unsubscribe – The AC E-Newsletter”.

**អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**ដើម្បីទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ**
dvandeth@arbitrationcouncil.org **ជាមួយប្រធានបទ** “Subscribe – The AC E-Newsletter”.

+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=

**ផ្ទះលេខ៧២ ផ្លូវ៥៩២ កែង ផ្លូវលេខ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក**
**ទូរសព្ទ: ៨៥៥ ២៣ ៨៨១ ៨១៤**
**ទូរសារ: ៨៥៥ ២៣ ៨៨១ ៨១៨**
**អ៊ីម៉ែល:** info@arbitrationcouncil.org
**វេបសាយ:** www.arbitrationcouncil.org